ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍

លេខ...០០៥...ស.ស.ក.ត.ទទ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពីវិធានការលុបបំបាត់ការប្រើពាក្យ "ទុកទុក" ដោយយកពាក្យ "រ៉ឺម៉ក" មកជំនួសវិញ

ក្រសួងទេសចរណ៍សូមជូនដំណឹងដល់សាធារណជន និងទេសចរជាតិ អន្តរជាតិទាំងអស់ឲ្យបានជ្រាបថា៖ បច្ចុប្បន្នមានការកើនឡើងឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃនៃទេសចរជាតិ និងអន្តរជាតិ ហើយប្រភេទសេវាកម្មទេសចរណ៍ផ្សេងៗក៏កំពុងតែជាទីពេញនិយមរបស់ភ្ញៀវផងដែរ។ ទន្ទឹមនេះយើងបានកត់សម្គាល់ឃើញថាសាធារណជនមួយចំនួនកំពុងតែមានការយល់ច្រឡំដោយប្រើពាក្យ "ទុកទុក" (Tuk Tuk) ចំពោះប្រភេទមធ្យោបាយដឹកជញ្ជូនលក្ខណៈជារ៉ឺម៉ក។ ដើម្បីរក្សានូវពាក្យដែលយើងធ្លាប់បានប្រើប្រាស់ជាយូរយារមកហើយ យើងត្រូវនាំគ្នាប្រើពាក្យ "**រ៉ឺម៉ក**" ជំនួសឲ្យពាក្យ "ទុកទុក" វិញជាប្រការល្អជាង។

អាស្រ័យដូចបានជំរាបជូនខាងលើ ក្រសួងទេសចរណ៍សូមសំណូមពរដល់សាធារណជន និងទេសចរជាតិ អន្តរជាតិទាំងអស់មេត្តាជួយផ្សព្វផ្សាយដើម្បីលើកតម្កើងការប្រើប្រាស់ពាក្យ "**រ៉ឺម៉ក**" ។

សូមលោក លោកស្រីទទួលនូវការរាប់អានអំពីខ្ញុំ ។

រដ្ឋមន្ត្រី

ថោង ខុន

**ចម្លងជូន**
- សាលារាជធានី ខេត្ត (ដើម្បីជូនជ្រាប)
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា
- សមាគមភោជនីយដ្ឋានកម្ពុជា
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- ប្រតិបត្តិករទេសចរណ៍

(ដើម្បីអនុវត្តន៍)

ឯកសារ-កាលប្បវត្តិ